# Embassy of Japan
# in the Kingdom of Cambodia

# Press Release

No. 10 PR-21/EoJ 01 March 2021

## Exchange of Notes
## for Japan's ODA Grant Aid

In response to a request from the Royal Government of Cambodia, and with a view to strengthening friendly and cooperative relations between Japan and the Kingdom of Cambodia, the Government of Japan has decided to extend its ODA Grant Aid to the Royal Government of Cambodia up to the amount of one billion, one hundred and thirty two million Japanese Yen (¥ 1,132,000,000), which is approximately equivalent to ten million eight hundred thousand USD ($ 10,800,000) for the "Project for the Development of Vessel Traffic System in Sihanoukville Port".

This project will establish the Vessel Traffic System (VTS) to improve maritime safety and efficiency of vessel navigation around the Sihanoukville Port. It is expected that safety measures at Sihanoukville port, the social and economic development of Cambodia and connectivity within the Mekong region will all be improved as a result of this project.

As Cambodia continues to develop its economy it is important that the quality of life of each and every citizen of the country with improve alongside national economic development. Japan would like to continue to support the Royal Government's efforts by utilising its various economic and social development schemes.

Notes to this effect were exchanged between **H.E. Mr. PRAK Sokhonn,** Deputy Prime Minister and Minister of Foreign Affairs and International Cooperation, and **H.E. Mr. MIKAMI Masahiro,** Ambassador of Japan to the Kingdom of Cambodia, on 1 March 2021.

---

*Embassy of Japan in the Kingdom of Cambodia*

*Tel: 023 217 161, Fax: 023 216 162,*

*Email: eco.jpn@pp.mofa.go.jp*

*Official Website: www.kh.emb-japan.go.jp*

# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

លេខៈ 10 PR-21/EoJ ថ្ងៃទី០១ ខែមិនា ឆ្នាំ២០២១

## លិខិតប្តូរសារសម្រាប់ផ្តល់ ហិរញ្ញប្បទានឥតសំណងរបស់ជប៉ុន

ឆ្លើយតបទៅនឹង សំណើររបស់រាជរដ្ឋាភិបាលកម្ពុជា និងដើម្បីពង្រឹងទំនាក់ទំនងមិត្តភាព ព្រមទាំងកិច្ចសហប្រតិបត្តិការរវាងជប៉ុន និងព្រះរាជាណាចក្រកម្ពុជា រដ្ឋាភិបាលជប៉ុនបានសម្រេចផ្តល់ហិរញ្ញប្បទានឥតសំណងចំនួន **មួយប៊ីលាន មួយរយសាមសិបពីរលានយ៉េន** (¥១ ១៣២ 000 000)ប្រមាណ **១០លាន៨សែនដុល្លារអាមេរិក** (១០ ៨00 000 USD) ដល់រាជរដ្ឋាភិបាលកម្ពុជាដើម្បីអនុវត្ត "គម្រោងអភិវឌ្ឍន៍ប្រព័ន្ធចរាចរនាវានៅកំពង់ផែស្វយត័ក្រុងព្រះសីហនុ"។

គម្រោងនេះនឹងបង្កើតប្រព័ន្ធចរាចរនាវា (VTS) ដើម្បីធ្វើឲ្យប្រសើរឡើងនូវសុវត្ថិភាពផ្លូវសមុទ្រនិងប្រសិទ្ធភាពការធ្វើនាវាចរណ៏នៅជុំវិញកំពង់ផែស្វយត័ក្រុងព្រះសីហនុ។ យើងរំពឹងថាតាមរយៈលទ្ធផលនៃគម្រោងនេះ វិធានការណ៍សុវត្ថិភាពនៅកំពង់ផែស្វយត័ក្រុងព្រះសីហនុ ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាព្រមទាំងការតភ្ជាប់ក្នុងតំបន់មេគង្គនឹងត្រូវបានលើកកម្ពស់។

ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាកំពុងតែបន្ត ការលើកកម្ពស់គុណភាពជីវភាពរស់នៅរបស់ប្រជាជនម្នាក់ៗស្របគ្នាទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ចជាតិទាំងមូលគឺមានសារៈសំខាន់ណាស់។ ជប៉ុនមានបំណងបន្តគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាដោយប្រើប្រាស់គ្រោងការណ៍អភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមនានា។

លិខិតប្តូរសារនៃគម្រោងនេះត្រូវបានចុះហត្ថលេខារវាងឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងឯកឧត្តម **មិកាមិ ម៉ាសាហ៊ីរ៉ូ** ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ១ ខែមិនាឆ្នាំ ២០២១។


*Embassy of Japan in the Kingdom of Cambodia*

*Tel: 023 217 161, Fax: 023 210 384*

*Email: eco.jpn@pp.mofa.go.jp*

*Official Website: www.kh.emb-japan.go.jp*